# ការរួចខ្លួនពីបទល្មើស៖

## ការអនុវត្តច្បាប់ចំពោះបទល្មើសរំលោភសេពសន្ថវៈ ក្នុងប្រព័ន្ធតុលាការកម្ពុជា



ដើម្បីប្រារព្ធយុទ្ធនាការ ១៦ថ្ងៃ នៃការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៥ អង្គការលីកាដូ បានចេញរបាយការណ៍វិភាគអំពីលទ្ធផលនៃករណីរំលោភសេពសន្ថវៈ ដែលត្រូវបានស៊ើបអង្កេតដោយអ្នកឃ្លាំមើលរបស់អង្គការលីកាដូ នៅក្នុងឆ្នាំ២០១២ ឆ្នាំ២០១៣ និងឆ្នាំ ២០១៤។

របាយការណ៍នេះ បង្ហាញឲ្យឃើញនូវភាពមិនប្រក្រតីយ៉ាងច្រើនជាប្រព័ន្ធនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ដែលជាលទ្ធផលជនល្មើសជាច្រើននៃអំពើរំលោភសេពសន្ថវៈ បានទទួលត្រឹមតែការផ្តន្ទាទោសស្រាលៗ តែប៉ុណ្ណោះ ឬក៏ត្រូវបានរួចខ្លួនទាំងស្រុងទៀតផង។

ប័ណ្ណព័ត៌មាននេះ បង្ហាញនូវព័ត៌មានមួយចំនួននៃលទ្ធផល និងអនុសាសន៍សំខាន់ៗ ដែលមាននៅក្នុងរបាយការណ៍នេះ។

## អាយុនៃជនរងគ្រោះ

ចន្លោះពីដើមឆ្នាំ ២០១២ ដល់ចុងឆ្នាំ ២០១៤ អង្គការលីកាដូ បានស៊ើបអង្កេត ៧៦២ ករណី នៃករណីរំលោភសេពសន្ថវៈ ឬបទប៉ុនប៉ងរំលោភសេពសន្ថវៈ ដែលពាក់ព័ន្ធនឹងជនរងគ្រោះ ចំនួន ៧៩៣ នាក់។ ភាគច្រើននៃជនរងគ្រោះទាំងនេះ មានអាយុក្រោម១៨ឆ្នាំ ដោយចំនួនមួយភាគធំស្ថិតក្នុងក្រុមអាយុពី ១២ឆ្នាំ ទៅ ១៧ ឆ្នាំ។ ជនរងគ្រោះ ៥៨ នាក់ ស្ថិតក្រោមអាយុ ៦ ឆ្នាំ (៧%) ១១៨ នាក់ មាន អាយុពី ៦ ទៅ ១១ ឆ្នាំ (២៣%) ៣២៨ នាក់ មានអាយុពី ១២ ទៅ ១៧ ឆ្នាំ (៤១%) និង ២២៦ នាក់ មានអាយុពី ១៨ ឆ្នាំឡើងទៅ (២៩%)។

**<u>អាយុនៃជនរងគ្រោះ</u>**

| | | |
|---|---|---|
| ក្រោម៦ឆ្នាំ | ៥៨ | ៧% |
| ៦ឆ្នាំ ទៅ ១១ឆ្នាំ | ១៨១ | ២៣% |
| ១២ឆ្នាំ ទៅ ១៧ឆ្នាំ | ៣២៨ | ៤១% |
| ១៨ឆ្នាំឡើងទៅ | ២២៦ | ២៩% |

## លទ្ធផលនៃករណី

គិតត្រឹម ខែសីហា ឆ្នាំ ២០១៥ ក្នុងចំណោម៧៦២ករណីដែលទទួលបាន មានករណីចំនួន ៤២៤ ត្រូវបានបញ្ចប់។ ត្រឹមតែមួយភាគបីតែប៉ុណ្ណោះនៃករណីនេះ ត្រូវបានបញ្ចប់ដោយការផ្តន្ទាទោសអំពីបទល្មើសរំលោភសេពសន្ថវៈ និងដាក់ទោសឲ្យជាប់ពន្ធនាគារ ដែលគោរពទៅតាមលក្ខខណ្ឌនៃក្រមព្រហ្មទណ្ឌ។ ចំណែកឯពីរភាគបីទៀត ដែលនៅសេសសល់នៃករណីទាំងនេះ ត្រូវបានបិទមុនការជំនុំជម្រះក្តី ឬបញ្ចប់ដោយការផ្តន្ទាទោសមិនត្រឹមត្រូវ ឬការសម្រេចឲ្យដោះលែងតែម្តង។

**<u>លទ្ធផលនៃករណីរំលោភសេពសន្ថវៈពាក់ព័ន្ធនឹងស្ត្រី និងកុមារ របស់អង្គការលីកាដូ ពីឆ្នាំ២០១២ ដល់២០១៤ ដែលត្រូវបានបញ្ចប់</u>**




## ការបញ្ចប់រឿងក្តីដោយសំណង

ក្នុងចំណោមករណីជាច្រើន ដែលត្រូវបានបិទមុនពេលជំនុំជម្រះក្តី មានករណីច្រើនជាងពាក់កណ្តាល (៧២ ករណី) ត្រូវបានបិទនៅពេលដែលជនរងគ្រោះបានធ្វើការដកពាក្យបណ្តឹងព្រហ្មទណ្ឌ បន្ទាប់ពីជនសង្ស័យបានបង់ប្រាក់សំណង។ ៥២ ករណី ក្នុងចំណោមករណីទាំងនោះ អង្គការ លីកាដូ បានទទួលព័ត៌មាន ទាក់ទងនឹងអ្នកដែលពាក់ព័ន្ធនៅក្នុងការចរចាសំណង៖ សំណង ៤៣ ករណី ត្រូវបានចរចាដោយនគរបាល ៦ ករណី ត្រូវបានចរចាដោយព្រះរាជអាជ្ញា និង ៣ ករណី ត្រូវបានចរចាដោយចៅក្រមស៊ើបសួរ។ អ្នកឃ្លាំមើលរបស់អង្គការលីកាដូ ជឿជាក់ថា ស្ទើរតែ ១០០% នៃករណីដែលត្រូវបានដោះស្រាយដោយការផ្តល់សំណង គឺមានពាក់ព័ន្ធនឹងការបង់ប្រាក់ក្រៅច្បាប់របស់ជនសង្ស័យទៅឲ្យមន្ត្រីសាធារណៈ។

ជនរងគ្រោះជ្រើសរើសបញ្ចប់រឿងក្តីដោយសំណង ដោយសារហេតុផលមួយចំនួន។ ដោយសារភាពអាម៉ាស់ ដែលបានកើតឡើងពីការចាប់រំលោភ ស្ត្រីជាច្រើនចង់ធានាថា មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះបានដឹងអំពីករណីរបស់ពួកគាត់។ វិធីមួយ ដើម្បីធ្វើបែបនេះ គឺការចរចារកដំណោះស្រាយមួយយ៉ាងឆាប់រហ័ស ដោយមិនចាំបាច់ចូលទៅតុលាការនោះទេ។ កត្តាទីពីរ គឺការចំណាយ និងផលលំបាកជាក់ស្តែងនៃការបន្តករណីតាមរយៈតុលាការ។ ប្រជាជនកម្ពុជាភាគច្រើនបានដឹងថា អំពើពុករលួយមួយចំនួនកើតមាននៅក្នុងប្រព័ន្ធតុលាការព្រហ្មទណ្ឌ ហើយដឹងថាអ្នកទាំងនោះនឹងមិនអាចមានលទ្ធភាពបង់ប្រាក់ក្រៅផ្លូវការ ដែលទាមទារឲ្យពួកគាត់ធ្វើការបង់នៅក្នុងដំណើរការទាំងមូលបាននោះទេ។ ជាចុងក្រោយ ក្នុងករណីដែលជនល្មើសមានតួនាទីសំខាន់ និងអំណាច ជនរងគ្រោះអាចមានអារម្មណ៍ថាគាត់ត្រូវបានបង្ខំឲ្យបញ្ចប់រឿងក្តី ដោយការគំរាមកំហែងពីខាងក្រៅ ឬពីខាងក្នុងថាជនសង្ស័យអាចនឹងចាត់វិធានការសងសឹក ប្រសិនបើជនរងគ្រោះមិនធ្វើការបញ្ចប់រឿងក្តីនោះទេ។

## ការរៀបអាពាហ៍ពិពាហ៍ជនរងគ្រោះ ទៅឲ្យជនសង្ស័យ

១១ ករណីត្រូវបានបញ្ចប់ដោយការរៀបអាពាហ៍ពិពាហ៍រវាងជនរងគ្រោះ និងជនសង្ស័យ។ ក្នុងនោះ ៣ ករណី នគរបាលបានជួយក្នុងការចរចាអាពាហ៍ពិពាហ៍ និងបានប្រាក់ពីការធ្វើការនេះ (១ករណី នគរបាលទទួលបានប្រាក់ ២.០០០ ដុល្លារ ពីក្រុមគ្រួសារជនសង្ស័យ)។ ៣ ករណី ព្រះរាជអាជ្ញាជាអ្នកសម្របសម្រួលការរៀបចំអាពាហ៍ពិពាហ៍ និង ១ករណី ចៅក្រមជំនុំជម្រះក្តី គឺជាភាគីនៃការរៀបចំអាពាហ៍ពិពាហ៍។

## ការរំលោភសេពសន្ថវៈនៅក្នុងចំណងអាពាហ៍ពិពាហ៍

១០ ករណី ស្ត្រីត្រូវបានស្វាមីរំលោភសេពសន្ថវៈ។ ក្នុងករណីទាំងនេះ ការរំលោភសេពសន្ថវៈបានកើតឡើងម្តងហើយម្តងទៀត និងជាផ្នែកមួយនៃលំនាំរយៈពេលវែងនៃអំពើហិង្សា និង ការរំលោភបំពានដោយស្វាមី។ ករណីចំនួន ៩ ក្នុងចំណោមករណីទាំងនោះ ត្រូវបានបញ្ចប់ដោយស្វាមី និងភរិយាលែងលះគ្នា និងគ្មានការកាត់ទោសព្រហ្មទណ្ឌនោះទេ។ មាន១ករណីដែលត្រូវបានធ្វើការជំនុំជម្រះក្តី ហើយជនល្មើសមិនត្រូវបានផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈទេ ប៉ុន្តែត្រូវបានចោទពីបទប្រើអំពើហិង្សាលើភរិយាទៅវិញ និងត្រូវបានផ្តន្ទាទោសក្នុងពន្ធនាគាររយៈពេលត្រឹមតែបីឆ្នាំ ដោយមានការព្យួរទោសពីរឆ្នាំ។

## ភាពក្រីក្រនិងពិការភាព

ជនរងគ្រោះ នៅពេលខ្លះបានដកពាក្យបណ្តឹងដោយខ្លួនឯងផ្ទាល់ ដោយមិនបានទទួលសំណងណាមួយនោះទេ។ មូលហេតុមួយក្នុងករណីនេះ គឺជាភាពក្រីក្រ។ ឧទាហរណ៍ ប្រសិនបើអ្នកទាំងនោះរស់នៅក្នុងតំបន់ជនបទដាច់ស្រយាល ជនរងគ្រោះដែលជាធម្មតាមិនអាចមានលទ្ធភាពចំណាយក្នុងការធ្វើដំណើរ ទៅកាន់ប៉ុស្តិ៍នគរបាល និងជាពិសេសគឺទៅកាន់តុលាការនោះទេ។ មូលហេតុមួយទៀត គឺពិការភាព ជាពិសេសគថ្លង់ ឬលំបាកក្នុងការសិក្សា។ ជានិច្ចជាកាលនៅក្នុងករណីបែបនេះ អង្គការមិនមែនរដ្ឋាភិបាលអាចផ្តល់នូវមូលនិធិនិងជំនួយពិសេស ដូចជាការផ្តល់សេវាបកប្រែ ប៉ុន្តែអង្គការទាំងនោះ មិនអាចធ្វើការនេះជាលក្ខណៈប្រព័ន្ធណាមួយបានទេ។ ជាលទ្ធផលជនរងគ្រោះប្រហែលជាមិនអាចបន្ត ពាក្យបណ្តឹងរបស់អ្នកទាំងនោះ



ក្មេងស្រីម្នាក់អាយុ ៩ឆ្នាំ ត្រូវបានចាប់រំលោភសេពសន្ថវៈ៥ដងដោយអ្នកជិតខាងអាយុ ២៣ឆ្នាំ។ គ្រួសារជនរងគ្រោះ បានរាយការណ៍អំពីករណីនេះ ទៅកាន់នគរបាលថ្នាក់ឃុំ ដែលជាអ្នកចរចាប្រាក់សំណងជាមួយជនសង្ស័យ។ គ្រួសារជនរងគ្រោះបានឯកភាពថា ពួកគេនឹងទទួលបានប្រាក់១.២០០ដុល្លារនិងដកពាក្យបណ្តឹងព្រហ្មទណ្ឌ។ ទីបំផុត ពេលដែលក្រុមគ្រួសារជនរងគ្រោះបានទទួលប្រាក់ពីនគរបាល អ្នកទាំងនោះបានទទួលត្រឹមតែ ៧០០ ដុល្លារ ប៉ុណ្ណោះ។ នគរបាលបាននិយាយថា ពួកគេបានយកប្រាក់នោះជាការទូទាត់ប្រាក់សម្រាប់ការជួយសម្រួលដល់កិច្ចព្រមព្រៀង សម្រាប់ការចំណាយលើការដឹកជញ្ជូន និងសម្រាប់ការបង់ប្រាក់ទៅឲ្យនគរបាលដទៃទៀត ដើម្បីធានាថាពួកគេនឹងមិនធ្វើការស៊ើបអង្កេត អំពីករណីនេះតទៅទៀត។



ស្ត្រីម្នាក់វ័យ ៣២ឆ្នាំ គឺជាជនរងគ្រោះនៃការប៉ុនប៉ងរំលោភសេពសន្ថវៈ ដោយមន្ត្រីនគរបាលថ្នាក់ឃុំ។ ប៉ុស្តិ៍នគរបាល គឺនៅជិតផ្ទះរបស់ស្ត្រីរងគ្រោះ ហើយការចរចាបានធ្វើឡើងនៅឯប៉ុស្តិ៍នគរបាលនោះ ដោយមានការសម្រួលដោយមិត្តរួមការងាររបស់ជនសង្ស័យ។ ជនរងគ្រោះទទួលបាន ៥០០ ដុល្លា ក្នុងការដកពាក្យបណ្តឹងព្រហ្មទណ្ឌប្តឹងមន្ត្រីនគរបាលនោះ។ សកម្មភាពតែមួយគត់របស់នគរបាល ដែលអនុវត្តទៅលើជនសង្ស័យ គឺធ្វើការផ្លាស់ប្តូរជននោះឲ្យទៅធ្វើការនៅប៉ុស្តិ៍នគរបាលមួយផ្សេងទៀត។



ស្ត្រីម្នាក់ គថ្លង់ វ័យ៣០ឆ្នាំ ត្រូវបានរំលោភសេពសន្ថវៈដោយអ្នកជិតខាង។ ដោយសារតែនាងមិនចេះភាសាគថ្លង់ នាងបានពឹងផ្អែកលើប្អូនស្រីរបស់នាង ដើម្បីបកប្រែឲ្យនាង។ ប្អូនស្រីរបស់នាង ដែលជាកម្មកររោងចក្រកាត់ដេរមួយ គឺជាអ្នកចាប់ផ្តើមជួយបងស្រីរបស់នាងក្នុងការដាក់ពាក្យបណ្តឹង។ ទោះជាយ៉ាងណា ដោយសារតែភាពក្រីក្ររបស់ក្រុមគ្រួសារ និងដោយសារអ្នកទាំងពីរមិនទទួលបានការគាំទ្រណាមួយ ប្អូនស្រីជនរងគ្រោះបានធ្វើការសម្រេចចិត្តដកពាក្យបណ្តឹង។ នាងមានការព្រួយបារម្ភថា ប្រសិនបើនាងចំណាយពេលវេលាឈប់ពីការងារដែលចាំបាច់ដើម្បីគាំទ្រករណីរបស់បងស្រីនាងនោះ នាងអាចនឹងបាត់បង់ការងាររបស់នាង។



ក្មេងស្រីម្នាក់អាយុ ៥ឆ្នាំ ត្រូវបានរំលោភសេពសន្ថវៈ ដោយអ្នកជិតខាងអាយុ ៥៥ ឆ្នាំ និងជាលទ្ធផលបានរងរបួសធ្ងន់ធ្ងរ។ ព្រះរាជអាជ្ញាបានចោទប្រកាន់ជនល្មើស ពីបទរំលោភសេពសន្ថវៈ ប៉ុន្តែក្រោយមកចៅក្រមស៊ើបសួរ បានផ្លាស់ប្តូរការចោទប្រកាន់ទៅជាបទប្រទូស្តកេរខ្មាស ដោយនិយាយថាជនរងគ្រោះមិនត្រូវបានជនល្មើសដាក់បញ្ចូលគ្រប់គ្រាន់ទេសម្រាប់ធ្វើឲ្យបទល្មើសនេះ ទៅជាបទល្មើសរំលោភសេពសន្ថវៈ។ ជនល្មើសត្រូវបានផ្តន្ទាទោសពីបទប្រទូស្តកេរខ្មាស និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល ១៨ ខែ ប៉ុន្តែចៅក្រមបានព្យួរទោសរយៈពេលមួយឆ្នាំ ដូច្នេះជនល្មើស បានជាប់ពន្ធនាគារត្រឹមតែប្រាំមួយខែប៉ុណ្ណោះ។ អ្នកឃ្លាំមើលនៅក្នុងករណីនេះគិតថា លទ្ធផលនេះ ប្រហែលកើតឡើងដោយសារមានការបង់ប្រាក់ក្រៅច្បាប់ទៅឲ្យចៅក្រមជំនុំជម្រះក្តី ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា។



កុមារីម្នាក់អាយុ ១៤ ឆ្នាំ ត្រូវបានរំលោភសេពសន្ថវៈ ដោយបុរសបីនាក់។ បុរសម្នាក់ត្រូវគេចាប់ខ្លួនបាន ហើយនាំយកទៅជំនុំជម្រះ។ មុនពេលសាលក្រម ត្រូវបានប្រកាស ក្រុមគ្រួសារនៃជនរងគ្រោះ និងក្រុមគ្រួសារនៃជនល្មើស បានយល់ព្រមលើកិច្ចព្រមព្រៀងថា អ្នកទាំងពីរនឹងរៀបអាពាហ៍ពិពាហ៍ ហើយថាឪពុកម្តាយជនល្មើសនឹងផ្តល់ប្រាក់មួយចំនួនទៅឲ្យគ្រួសារជនរងគ្រោះ។ ពួកគេបានឲ្យប្រាក់ទៅចៅក្រមជំនុំជម្រះក្តី ដែលជាអ្នកកាត់ទោសជនល្មើសពីបទរំលោភសេពសន្ថវៈ និងឲ្យជាប់ពន្ធនាគារ ១៨ ខែ ហើយបន្ទាប់មក ទោសក៏ត្រូវបានព្យួរទាំងស្រុង។ អ្នកឃ្លាំមើល ដែលជាប់ពាក់ព័ន្ធ បានព្យាយាមនិយាយជាមួយគ្រួសារជនរងគ្រោះកុំឲ្យបន្តទៅមុខជាមួយនឹងអាពាហ៍ពិពាហ៍នេះ។ ម្តាយជនរងគ្រោះបានឆ្លើយថា អ្នកស្រីមិនចង់ឲ្យកូនស្រីរបស់គាត់រៀបអាពាហ៍ពិពាហ៍ទេ ប៉ុន្តែសម្រាប់នៅជនបទ ការសម្រេចរៀបអាពាហ៍ពិពាហ៍ឲ្យកូនស្រីគាត់ រួចលែងលះគ្នាវាប្រសើរជាងការមិនទាន់បានរៀបអាពាហ៍ពិពាហ៍ តែត្រូវគេដឹងថានាងត្រូវបានគេចាប់រំលោភ។

បានទេ។ ពេលខ្លះជនរងគ្រោះ ប្រឈមមុខនឹងផលលំបាកជាច្រើន ដែលធ្វើឲ្យមានការលំបាកសម្រាប់ពួកគាត់ក្នុងការបន្តសំណុំរឿងក្តីរបស់អ្នកទាំងនោះ។

## ការផ្តន្ទាទោសមិនត្រឹមត្រូវ និងការផ្តន្ទាទោសកម្រិតទាប

ពីរភាគបីនៃករណីដែលត្រូវបានបិទ បានបញ្ចប់ដោយការផ្តន្ទាទោស ប៉ុន្តែប្រហែលពាក់កណ្តាលនៃការផ្តន្ទាទោសនោះ គឺមានកំហុសមួយចំនួន និងបានដាក់ទោសក្នុងកម្រិតទាបខ្លាំង។ កំហុសទាំងនេះបាន កើតឡើងដោយសារមូលហេតុជាច្រើនខុសៗគ្នា ប៉ុន្តែជាញឹកញាប់ គឺជាលទ្ធផលនៃការអនុវត្តខុសពីច្បាប់ ការសម្រេចចិត្តផ្តន្ទាទោសនៅខ្សោយ និងអំពើពុករលួយ។

## អនុសាសន៍

**►►►ជំហានជាច្រើន គួរតែត្រូវបានអនុវត្ត ដើម្បីធានាថាគ្រប់ជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈទាំងអស់ (ទាំងបុរស និងស្ត្រី) មានអារម្មណ៍ជឿជាក់ក្នុងការរាយការណ៍បទល្មើស។ ជំហានទាំងនេះរួមមាន៖**

ទីមួយ៖ មន្ត្រីជាន់ខ្ពស់ក្នុងជួររាជរដ្ឋាភិបាល នគរបាល និងមន្ត្រីផ្នែកតុលាការ គួរធ្វើការថ្កោលទោសលើអំពើរំលោភសេពសន្ថវៈ និងធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ម្តងហើយម្តងទៀតស្តីពីការប្តេជ្ញាចិត្ត របស់អ្នកទាំងនោះ ដើម្បីដាក់ទណ្ឌកម្មទៅលើគ្រប់ជនល្មើសទាំងអស់។

ទីពីរ៖ ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្តីពីគ្រោះថ្នាក់ ដែលបណ្តាលមកពីអំពើរំលោភសេពសន្ថវៈ និងច្បាប់ព្រហ្មទណ្ឌស្តីពីបទល្មើសផ្លូវភេទ ដោយប្រើប្រាស់គ្រប់ទម្រង់ នៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងបណ្តាញព័ត៌មានសង្គម និងផ្សព្វផ្សាយដោយផ្ទាល់ទៅកាន់កុមារនៅក្នុងសាលារៀនទៀតផង។

ទីបី៖ ធ្វើកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល (ជាពិសេស ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌) ជាមួយនឹងបណ្តាញអ្នកធ្វើការងារផ្នែកកំសាន្ត ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវការរាយការណ៍របស់អ្នកធ្វើការងារផ្នែកកំសាន្ត អំពីអំពើរំលោភសេពសន្ថវៈ និងធានាថាករណីនៃបទល្មើសទាំងអស់នេះត្រូវបានស៊ើបអង្កេត ហើយជនល្មើសទាំងអស់ត្រូវបានផ្តន្ទាទោសតាមច្បាប់ ដោយមិនមានផលវិបាកវិលត្រឡប់មកកាន់ជនរងគ្រោះវិញ។

**►►► រាជរដ្ឋាភិបាល គួរតែចាត់វិធានការនានាដើម្បីធានាថាគ្រប់ករណីនៃអំពើរំលោភសេពសន្ថវៈទាំងអស់**

**ត្រូវបានស៊ើបអង្កេតឲ្យបានត្រឹមត្រូវ និងគ្រប់ឧបសគ្គ រារាំងនីតិវិធីសវនាការរបស់តុលាការ គួរតែត្រូវបានលុបបំបាត់។ វិធានការទាំងអស់នោះ រួមមាន៖**

ទីមួយ៖ ផ្តល់នូវធនធានឲ្យបានគ្រប់គ្រាន់ជូនដល់នគរបាល ដើម្បីធានាថាគ្រប់ករណីនៃបទល្មើសរំលោភសេពសន្ថវៈទាំងអស់ ត្រូវបានស៊ើបអង្កេតឲ្យបានពេញលេញ និងទាន់ពេលវេលា ភស្តុតាងត្រូវបានប្រមូលឲ្យបានត្រឹមត្រូវ និងគ្រប់ជនសង្ស័យទាំងអស់ត្រូវបានចាប់ខ្លួន។

ទីពីរ៖ ការបង្កើតនិងការអនុវត្តនីតិវិធីនានា និងការផ្តល់ការបណ្តុះបណ្តាលដល់នគរបាល ព្រះរាជអាជ្ញា ចៅក្រម និងបុគ្គលិកពេទ្យនានា ស្តីពីរបៀបប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះពីបទល្មើសហិង្សាផ្លូវភេទទាំងពីរភេទ ជាពិសេសជនរងគ្រោះជាកុមារ រួមទាំងអ្នកដែលមានការលំបាកនានាក្នុងការរៀនសូត្រ ដែលជាអ្នកត្រូវបានសាកសួរ ឬ ផ្តល់ភស្តុតាងនៅក្នុងតុលាការ ឬប៉ុស្តិ៍នគរបាល។

ទីបី៖ ការបង្កើតនូវមូលនិធិពិសេសរបស់រាជរដ្ឋាភិបាល សម្រាប់ជនរងគ្រោះក្រីក្រមិនមានលទ្ធភាពបន្តនីតិវិធីព្រហ្មទណ្ឌនានា សម្រាប់ចំណាយផ្សេងៗក្នុងករណីនេះដូចជា ថ្លៃធ្វើដំណើរ និងជាប្រាក់សំណងខូចខាតសម្រាប់ចំនួនថ្ងៃធ្វើការងារ ដែលជនរងគ្រោះបានបាត់បង់ជាដើម។

ទីបួន៖ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ គួរផ្តល់នូវអ្នកបកប្រែភាសាគថ្លង់ សម្រាប់ជនរងគ្រោះដែលជាមនុស្សគថ្លង់ ដែលចាំបាច់នៅពេលនៅក្នុងប៉ុស្តិ៍នគរបាល និងក្នុងតុលាការ។

ទីប្រាំ៖ ធ្វើការកាត់ទោសឲ្យបានម៉ឺងម៉ាត់ទៅលើគ្រប់ករណីទាំងអស់នៃបទល្មើសហិង្សាលើផ្លូវភេទ ដោយមិនគិតលើឋានៈ ឥទ្ធិពល ឬទ្រព្យសម្បត្តិរបស់ជនល្មើសនោះទេ។ ចាប់ផ្តើមនិងបន្តនីតិវិធីស៊ើបអង្កេតដោយព្រះរាជអាជ្ញា ដែលរួមទាំងចំពោះករណីដែលជនរងគ្រោះមិនទាន់បានដាក់ ឬបានដាក់ពាក្យបណ្តឹងប៉ុន្តែក្រោយមកបានដកវិញ។

ទីប្រាំមួយ៖ ពង្រឹងការអនុវត្តមាត្រានានានៅក្នុងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះមន្ត្រីនគរបាលណាដែលមិនបានចាប់ផ្តើមនីតិវិធី ឬរារាំងមិនឲ្យចាប់ផ្តើមនីតិវិធីបន្ទាប់ពីទទួលបានការបង់ប្រាក់ក្រៅច្បាប់។

ទីប្រាំពីរ៖ ការពង្រឹងការអនុវត្តមាត្រានានានៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពើពុករលួយ ចំពោះមន្ត្រីនគរបាលនានា ត្រង់ចំណុចអំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីសាធារណៈ។

ទីប្រាំបី៖ អនុវត្តគោលការណ៍លើកលែងទោស ចំពោះជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈណា ដែលបានទទួលប្រាក់សំណងក្រៅផ្លូវការ ប៉ុន្តែបានរាយការណ៍អំពីអំពើពុករលួយដែលពាក់ព័ន្ធនឹងមន្ត្រីសាធារណៈ ដែលធ្វើការលើសំណុំរឿងរំលោភសេពសន្ថវៈនោះ។

**►►►ជំហាននានាគួរតែត្រូវបានអនុវត្ត ដើម្បីធានាថាសវនាការត្រូវបានប្រព្រឹត្តទៅដោយត្រឹមត្រូវ និងទណ្ឌកម្មត្រូវបានគេអនុវត្តឲ្យបានស៊ីចង្វាក់ និងត្រឹមត្រូវ។ ជំហានទាំងអស់នេះរួមមាន៖**

ទីមួយ៖ ផ្តល់ការបណ្តុះបណ្តាលដល់ចៅក្រមទាំងចាស់ ទាំងថ្មី ស្តីពីមាត្រានានាក្នុងក្រមព្រហ្មទណ្ឌ ដែលពាក់ព័ន្ធនឹងបទល្មើសរំលោភសេពសន្ថវៈ ដើម្បីធានាថា ចៅក្រមទាំងនោះយល់ដឹងច្បាស់ពីអត្ថន័យទាំងស្រុង រួមមានជនរងគ្រោះជាបុរស ការរួមភេទដោយប្រើមាត់ និងជនល្មើសជាស្ត្រី ហើយនិងដើម្បីឲ្យចៅក្រមទាំងនោះបានដឹងអំពីស្ថានទម្ងន់ទោស និងទោសទណ្ឌនានា។

ទីពីរ៖ ការបង្កើតនូវការណែនាំនានាសម្រាប់ចៅក្រម ស្តីពីការដកចេញពីសវនាការ នូវភស្តុតាងដែលពាក់ព័ន្ធនឹងប្រវត្តិផ្លូវភេទរបស់ជនរងគ្រោះ លើកលែងតែនៅក្នុងករណីពិសេសនានាដែលពាក់ព័ន្ធនឹងរឿងនេះ។

ទីបី៖ ការបំបែកចេញពីគ្នារវាងធាតុផ្សំផ្នែកករណីព្រហ្មទណ្ឌ និងករណីរដ្ឋប្បវេណី នៃបទល្មើសរំលោភសេពសន្ថវៈ ដូចនេះករណីទាំងពីរនេះអាចត្រូវបានដោះស្រាយដោយតុលាការ និងចៅក្រមពីរប្រភេទផ្សេងគ្នា។

ទីបួន៖ ពង្រឹងការអនុវត្តមាត្រានានានៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពីពុករលួយ ចំពោះចៅក្រម និងព្រះរាជអាជ្ញាទាំងឡាយ ត្រង់ចំណុចអំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីសាធារណៈ។

ទីប្រាំ៖ ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដើម្បីធ្វើឲ្យបានច្បាស់ថា បទល្មើសរំលោភសេពសន្ថវៈ ត្រូវរួមមានទាំងអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ហើយអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ មិនគួរត្រូវបានផ្តន្ទាទោសយោងតាមមាត្រាស្តីពីហិង្សាដែលប្រព្រឹត្តដោយសហព័ន្ធ ឬដៃគូនោះទេ។

ទីប្រាំមួយ៖ បញ្ជាក់ឲ្យច្បាស់នូវអត្ថន័យពាក់ព័ន្ធនឹងជនរងគ្រោះក្នុងឃ្លាថា៖ "ភាពងាយរងគ្រោះ ដោយមូលហេតុអាយុនៃបុគ្គលនោះ" នៅក្នុងក្រមព្រហ្មទណ្ឌ ត្រង់ចំណុចស្ថានទម្ងន់ទោសសម្រាប់បទល្មើសរំលោភសេពសន្ថវៈ និងផ្តល់ការបណ្តុះបណ្តាលដល់ចៅក្រម ដើម្បីធានាថាមាត្រានេះ ត្រូវបានអនុវត្តដោយស៊ីចង្វាក់គ្នាគ្រប់ករណីក្នុងពេលកាត់ទោសជនល្មើស។

ទីប្រាំពីរ៖ ធ្វើវិសោធនកម្មច្បាប់ ដើម្បីកំណត់ថាមិនគួរមានការព្យួរទោសចំពោះការផ្តន្ទាទោសលើបទល្មើសរំលោភសេពសន្ថវៈនោះទេ។

ទីប្រាំបី៖ ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដើម្បីបញ្ចូលមាត្រាដែលកំណត់ថាការប៉ុនប៉ងរំលោភសេពសន្ថវៈនឹងត្រូវទទួលទោសទណ្ឌដូចបទល្មើសរំលោភសេពសន្ថវៈផងដែរ។


**ទំនាក់ទំនងយើង**

- ការិយាល័យកណ្តាល (ភ្នំពេញ) ទូរស័ព្ទលេខ៖ ០២៣ ៧២៧ ១០២/២១៦ ៦០២
- ខេត្តបន្ទាយមានជ័យ ទូរស័ព្ទលេខ៖ ០៥៤ ៩៥៨ ៨៦១
- ខេត្តបាត់ដំបង ទូរស័ព្ទលេខ៖ ០៥៣ ៩៥២ ៨២៨
- ខេត្តកំពង់ចាម ទូរស័ព្ទលេខ៖ ០៤២ ៩៤១ ៦៦៤
- ខេត្តកំពង់ឆ្នាំង ទូរស័ព្ទលេខ៖ ០២៦ ៩៨៨ ៦៣៧
- ខេត្តកំពង់ស្ពឺ ទូរស័ព្ទលេខ៖ ០២៥ ៩៨៧ ២២០
- ខេត្តកំពង់ធំ ទូរស័ព្ទលេខ៖ ០៦២ ៩៦១ ២៩២
- ខេត្តកំពត ទូរស័ព្ទលេខ៖ ០៣៣ ៩៣២ ៦៦៣
- ខេត្តកោះកុង ទូរស័ព្ទលេខ៖ ០៣៥ ៩៣៦ ១១៦
- ខេត្តពោធិ៍សាត់ ទូរស័ព្ទលេខ៖ ០៥២ ៩៥១ ៤៩៦
- ខេត្តរតនគិរី ទូរស័ព្ទលេខ៖ ០៦៦ ៨៨៨ ៥៥៨
- ខេត្តសៀមរាប ទូរស័ព្ទលេខ៖ ០៦៣ ៩៦៤ ០៦៦
- ខេត្តព្រះសីហនុ ទូរស័ព្ទលេខ៖ ០៣៤ ៩៣៣ ៧១៦
- ខេត្តស្វាយរៀង ទូរស័ព្ទលេខ៖ ០៤៤ ៩៤៥ ៨៣៣